## ធនធាន

សម្រាប់ការបញ្ជូនទៅសេវាកម្មច្បាប់តម្លៃទាប ឬឥតគិតថ្លៃក្នុងតំបន់របស់អ្នក (បើអ្នកមានគុណសម្បត្តិគ្រប់គ្រាន់) ទូរស័ព្ទទៅប្រព័ន្ធការអប់រំ ដំបូន្មាន និងការបញ្ជូនផ្នែកច្បាប់ដែលបានសម្របសម្រួល (CLEAR) សម្រាប់រដ្ឋវ៉ាស៊ីនតោន ៖

**CLEAR**
888-201-1014
ឬចូលទៅ ៖ www.washingtonlawhelp.org

### ច្បាប់

- ច្បាប់ជំនួយគ្រួសារអន្តររដ្ឋតែមួយ (UIFSA) RCW 26.21A
- ផ្នែក 459A(a) នៃចំណងជើង Title IV-D នៃច្បាប់សន្តិសុខសង្គម 42.USC 659A(a)

**ដើម្បីទាក់ទងរដ្ឋផ្សេងទៀតចូលទៅ ៖**
www.acf.hhs.gov/programs/css

**តុលាការ**
www.courts.wa.gov/

**ផ្នែកជំនួយកុមារ**
www.dshs.wa.gov/dcs/

**អ៊ីមែល**
DCS-CRU@dshs.wa.gov

**សំណួរជំនួយកុមារអន្តរជាតិ**
ocseinternational@acf.hhs.gov

ឬ

travel.state.gov

### ការិយាល័យផ្នែកជំនួយកុមារ ៖

| | |
|---|---|
| Everett | 800-729-7580<br>425-438-4800 |
| Kennewick | 800-345-9981<br>509-374-2000 |
| Olympia | 800-345-9964<br>360-664-6900 |
| Seattle | 800-526-8658<br>206-341-7000 |
| Spokane | 800-345-9982<br>509-363-5000 |
| Tacoma | 800-345-9976<br>253-597-3700 |
| Vancouver | 800-345-9984<br>360-696-6100 |
| Wenatchee | 800-535-1113<br>509-886-6800 |
| Yakima | 800-441-0859<br>509-249-6000 |
| ទីស្នាក់ការ | 800-457-6202<br>360-664-5000 |

បើអ្នកចង់បើកសំណុំរឿងជាមួយផ្នែកជំនួយកុមារ អ្នកអាចទៅការិយាល័យជំនួយកុមារក្នុងតំបន់របស់អ្នក សូមទាក់ទងពួកយើងតាមលេខ 800-442-KIDS (5437) ឬចូលគេហទំព័ររបស់ពួកយើង ៖
www.childsupportonline.wa.gov

Washington State
Department of Social & Health Services
Transforming lives

DSHS 22-021 CA (Rev. 5/16) Cambodian

កម្មវិធីជំនួយកុមាររបស់រដ្ឋវ៉ាស៊ីនតោន



# ការប្រមូលជំនួយកុមារឆ្លងព្រំដែន

Washington State
Department of Social & Health Services
Transforming lives

## តើខ្ញុំអាចប្រមូលជំនួយកុមារបានទេ បើឪពុក ឬម្ដាយម្ខាងទៀតស្ថិតក្នុងរដ្ឋមួយទៀត?

បាទ/ចាស ។ ពេលដែលឪពុក ឬម្ដាយម្ខាងទៀតរស់នៅក្នុងរដ្ឋមួយទៀត ផ្នែកជំនួយកុមារ (DCS) អាចផ្ញើសេចក្ដីជូនដំណឹងសម្រាប់ការកាត់ទុកប្រាក់ឈ្នួល និងធានារ៉ាប់រងសុខភាពដោយផ្ទាល់ទៅនិយោជិត ។

ពេលខ្លះ DCS ស្នើសុំរដ្ឋផ្សេងដើម្បីជួយជំរុញដីកាជំនួយ ។ ពេលដែលពួកយើងផ្ញើការបញ្ជូនទៅរដ្ឋមួយទៀត ពួកយើងមិនអាចប្រាប់រដ្ឋផ្សេងពីរបៀបដំណើរការសំណុំរឿងទេ ។ រដ្ឋនីមួយៗមានច្បាប់ និងគោលនយោបាយជំនួយកុមារផ្ទាល់ខ្លួន ។

DCS ក៏អាចប្រមូលពីឪពុក ឬម្ដាយក្នុងរដ្ឋវ៉ាស៊ីនតោនសម្រាប់ឪពុក ឬម្ដាយមានសិទ្ធិចិញ្ចឹមដែលរស់នៅក្នុងរដ្ឋមួយទៀត ។

## តើខ្ញុំស្នើសុំសេវាកម្ម DCS យ៉ាងដូចម្ដេច?

បើអ្នកទទួលបានជំនួយសាធារណៈពីរដ្ឋវ៉ាស៊ីនតោន DCS កំពុងធ្វើការដើម្បីប្រមូលជំនួយ ។ DCS អាចស្នើសុំអ្នកធ្វើបច្ចុប្បន្នភាពព័ត៌មានអំពីអាសយដ្ឋាន ឬនិយោជិតរបស់ឪពុក ឬម្ដាយម្ខាងទៀត ។

បើអ្នកជឿជាក់ថាសកម្មភាព DCS អាចបង្កគ្រោះថ្នាក់ដល់អ្នក ឬកូនក្នុងគ្រួសារអ្នក ទាក់ទងការិយាល័យសេវាកម្មសហគមន៍ដើម្បីស្នើសុំ "មូលហេតុល្អមិនសហការជាមួយ DCS" ។

បើអ្នកមានអារម្មណ៍ថាការបញ្ចេញអាសយដ្ឋាន ឬព័ត៌មានផ្សេងទៀតដល់ភាគីផ្សេងអាចបង្កគ្រោះថ្នាក់ ប្រាប់ DCS ហើយពួកយើងអាចប្រាប់រដ្ឋផ្សេងឲ្យរក្សាព័ត៌មានជាសម្ងាត់ ។

បើអ្នកមិនបានទទួលជំនួយសាធារណៈ DCS ផ្ដល់សេវាកម្មជំរុញឲ្យអ្នកតាមសំណើជាលាយលក្ខណ៍អក្សរ ។ អ្នកអាចទទួលបានបែបបទលើបណ្ដាញនៅ https://www.dshs.wa.gov/esa/faq?field_topic_value=childservice ។



## តើត្រូវចំណាយពេលប៉ុន្មានដើម្បីប្រមូលជំនួយកុមារពីរដ្ឋមួយទៀត?

បើ DCS ស្នើសុំឲ្យរដ្ឋផ្សេងជួយ វាអាចចំណាយពេលយូរដើម្បីរៀបចំសំណុំរឿងរបស់អ្នក ។ កត្តាផ្សេងទៀតដែលអាចពន្យាការរៀបចំសំណុំរឿងរួមមានសកម្មភាពនានាដោយឪពុក ឬម្ដាយម្ខាងទៀត ដូចជា ៖

- ការផ្លាស់ប្ដូរពីការងារមួយទៅការងារមួយទៀត
- ការផ្លាស់ប្ដូរកន្លែងស្នាក់នៅញឹកញាប់ ។
- ការក្លាយជាគ្មានការងារធ្វើ និងមិនទទួលបានសំណងគ្មានការងារធ្វើ ។
- ការធ្វើការសម្រាប់សាច់ប្រាក់ ។
- ការធ្វើការឲ្យខ្លួនឯង ។
- ការទទួលបានជំនួយសាធារណៈ ។
- ការជាប់ពន្ធនាគារ ឬកន្លែងស្ដារនីតិសម្បទា ។
- ការរស់នៅក្នុងដីបម្រុងជនជាតិឥណ្ឌាស្បែកក្រហម ។
- ការទទួលការងារដោយកុលសម្ព័ន្ធ សហគ្រាសកុលសម្ព័ន្ធ ឬមុខជំនួយដែលជនជាតិឥណ្ឌាស្បែកក្រហមជាម្ចាស់ដែលមានទីតាំងក្នុង ដីបម្រុងជនជាតិឥណ្ឌាស្បែកក្រហម ឬដីឯកោធិកម្ម ។

## ចុះបើរដ្ឋផ្សេងមិនជោគជ័យ?

គ្រប់សំណុំរឿងទាំងអស់ រដ្ឋទាំងពីរបន្តពិនិត្យធនធានសហព័ន្ធ រដ្ឋ និងក្នុងតំបន់សម្រាប់អាសយដ្ឋាន និងទ្រព្យរបស់ឪពុក ឬម្ដាយម្ខាងទៀត ។

## តើមានការគិតប្រាក់សម្រាប់សេវាកម្មទាំងនេះទេ?

DCS គិតថ្លៃម្ភៃប្រាំដុល្លារ ($25) សម្រាប់ឆ្នាំសហព័ន្ធនីមួយៗ (រវាងថ្ងៃទី 1 ខែតុលា និងថ្ងៃទី 30 ខែកញ្ញា) បើឪពុក ឬម្ដាយមានសិទ្ធិចិញ្ចឹមមិនដែលបានទទួល TANF ឬ AFDC ហើយបើ DCS បានចេញប្រាក់ $500 ឬច្រើនជាងនេះដល់គ្រួសារលើសំណុំរឿងក្នុងអំឡុងឆ្នាំ ។

បើរដ្ឋមួយទៀតជួយប្រមូលជំនួយ រដ្ឋនោះអាចគិតប្រាក់ ឬទាញយកចំណាយនៃសេវាកម្មរបស់ពួកគេ ។ រដ្ឋអាចគិតប្រាក់ពីឪពុក ឬម្ដាយបង់ប្រាក់ ឬឪពុក ឬម្ដាយមានសិទ្ធិចិញ្ចឹម ។រដ្ឋអាចដកការគិតប្រាក់ទាំងនេះពីជំនួយដែលបានប្រមូលពីឪពុក ឬម្ដាយបង់ប្រាក់ ។

## តើរដ្ឋផ្សេងអាចផ្លាស់ប្ដូរបរិមាណទូទាត់ជំនួយ ឬបរិមាណសងជំនួយដែលឪពុក ឬម្ដាយម្ខាងទៀតជំពាក់ខ្ញុំបានទេ?

រដ្ឋត្រូវតែផ្ដល់កិត្តិយសដល់ដីកា ដូចត្រូវបានសសេរដោយរដ្ឋមួយទៀត ។ រដ្ឋទាំងអស់ជំរុញតែដីកាមួយប៉ុណ្ណោះសម្រាប់ភាគីដដែល ។ គ្រប់ពេល ឪពុក ឬម្ដាយ ណាមួយអាចប្ដឹងសម្រាប់ការកែប្រែបរិមាណជំនួយកុមារប្រចាំខែ ។

## តើខ្ញុំអាចប្រមូលជំនួយកុមារបានទេ បើឪពុក ឬម្ដាយម្ខាងទៀតរស់នៅក្នុងប្រទេសផ្សេង?

ពេលខ្លះ ។ DCS មានកិច្ចព្រមព្រៀងអន្តរជាតិដែលអនុញ្ញាតឲ្យពួកយើងធ្វើការជាមួយប្រទេសជាច្រើន ។ ដើម្បីពិនិត្យពីប្រទេស សូមទូរស័ព្ទមកពួកយើងតាមលេខ 1-800-457-6202។

## ខ្ញុំគ្មានដីកាជំនួយ ។ តើខ្ញុំទទួលបានមួយយ៉ាងដូចម្ដេច?

ដីកាជំនួយអាចត្រូវបានបង្កើត បើឪពុក ឬម្ដាយម្ខាងទៀតមិនរស់នៅទីនេះ ។ ដើម្បីទទួលបានពាក្យសុំសេវាកម្មជំរុញជំនួយ សូមទូរស័ព្ទទៅលេខ 800-442-KIDS (5437) ឬទូរស័ព្ទទៅការិយាល័យដែលនៅជិតអ្នកបំផុត ដែលមាននៅខាងក្រោយខិតប័ណ្ណនេះ ឬមានលើបណ្ដាញនៅ ៖ http://www.dshs.wa.gov/esa/child-support-find-an-office ។

## រាល់ព័ត៌មានទាំងអស់ក្នុងកំណត់ត្រា DCS គឺជាការសម្ងាត់ ។

អ្នកអាចមាននរណាម្នាក់ (សាច់ញាតិ មិត្តភក្ដិ ឬអ្នកតំណាងស្របច្បាប់) ទូរស័ព្ទទៅ DCS ជំនួសឲ្យអ្នក ។ ពួកយើងអាចឆ្លើយសំណួរទូទៅសម្រាប់នរណាមួយ ប៉ុន្តែពួកយើងមិនអាចពិភាក្សាព័ត៌មានលម្អិតជាក់លាក់នៃសំណុំរឿង លុះត្រាតែពួកយើងមានការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នក ។